ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៤៨ ស.ស.រ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារចំពោះកិច្ច ទទួលបន្ទុកសិក្សា និងផ្តល់យោបល់ លើស្ថានភាពពន្ធ និងអាករ និងបរិយាកាសវិនិយោគក្នុងព្រះរាជាណាចក្រកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ២៧៦ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការបង្កើតខុទ្ទកាល័យឯកឧត្តមកិត្តិទេសាភិបាលបណ្ឌិត **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតក្រុមការងារចំពោះកិច្ច ទទួលបន្ទុកសិក្សា និងផ្តល់យោបល់លើស្ថានភាពពន្ធ និងអាករ និងបរិយាកាសវិនិយោគក្នុងព្រះរាជាណាចក្រកម្ពុជា ចំណុះខុទ្ទកាល័យនាយករដ្ឋមន្ត្រី ដែលមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| ១. ឯកឧត្តម **សុខ សារាវុឌ្ឍ** | ប្រធាន |
| ២. ឯកឧត្តម **សុខ ពិសិដ្ឋ** | អនុប្រធាន |
| ៣. ឯកឧត្តម **ម៉ុក ច័ន្ទសុធា** | អនុប្រធាន |
| ៤. ឯកឧត្តម **យន ម៉ាលីមឆេង** | សមាជិក |
| ៥. ឯកឧត្តម **គីម មិនា** | សមាជិក |



https://www.moj.gov.kh/kh/law-regular

៦. លោក **ឡើន ម៉ុនហេង** សមាជិក

៧. លោក **ចាន់ ខាសនា** សមាជិក

៨. លោក **អ៊ុង សិរីមង្គល** សមាជិក

ការតែងតាំង និងការផ្លាស់ប្ដូរសមាសភាព នៃក្រុមការងារចំពោះកិច្ច ត្រូវធ្វើឡើងតាមការសម្រេចរបស់នាយករដ្ឋមន្ត្រី ដោយយោងតាមការស្នើរបស់ប្រធានក្រុមការងារចំពោះកិច្ច។

ក្រុមការងារចំពោះកិច្ច អាចបង្កើតក្រុមការងារចំណុះតាមការចាំបាច់ តាមការសម្រេចរបស់នាយករដ្ឋមន្ត្រី ដោយយោងតាមការស្នើរបស់ប្រធានក្រុមការងារចំពោះកិច្ច ដើម្បីអនុវត្តភារកិច្ចរបស់ខ្លួន។

**ប្រការ២ ..**

ក្រុមការងារចំពោះកិច្ច មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ធ្វើជាសេនាធិការជូននាយករដ្ឋមន្ត្រី ក្នុងការផ្ដល់យោបល់លើស្ថានពន្ធ និងអាករ និងបរិយាកាសវិនិយោគក្នុងព្រះរាជាណាចក្រកម្ពុជា
- សិក្សាអំពីអនុលោមភាព នៃការអនុវត្តពន្ធ និងអាករ និងអត្ថប្រយោជន៍សម្រាប់ការវិនិយោគ ក្នុងព្រះរាជាណាចក្រកម្ពុជា
- សិក្សាស្រាវជ្រាវបញ្ហាប្រឈម និងសំណូមពរ របស់វិនិយោគិនពាក់ព័ន្ធនឹងពន្ធ និងអាករ
- សម្របសម្រួល ទំនាក់ទំនង និងសហការជាមួយក្រសួង-ស្ថាប័នថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ វិនិយោគិន និងបណ្ដាភាគីពាក់ព័ន្ធ ដើម្បីសម្រេចភារកិច្ច ប្រកបដោយប្រសិទ្ធភាពខ្ពស់
- បំពេញភារកិច្ចផ្សេងទៀត តាមការប្រគល់ពីនាយករដ្ឋមន្ត្រី។

**ប្រការ៣ ..**

ក្រុមការងារចំពោះកិច្ច មានថវិកាសម្រាប់ដំណើរការការងារ ក្នុងកញ្ចប់ថវិការបស់ខុទ្ទកាល័យនាយករដ្ឋមន្ត្រី។

**ប្រការ៤ ..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្ដីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ៥ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៤ រោច ខែ មាឃ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



https://www.moj.gov.kh/kh/law-regular